# សំនួរដែលអ្នកជំងឺតែងសួរជាញឹកញាប់

## តើថ្នាំមានផលរំខានអ្វីដែរឬទេ?

អ្នកជំងឺភាគច្រើនមិនមានបញ្ហាជាមួយនឹងថ្នាំទាំងនោះទេ ប៉ុន្តែអ្នកជំងឺខ្លះក៏មានតិចតួចដែរ ។

ថ្នាំអាចធ្វើឱ្យទឹកនោមរបស់អ្នកមានពណ៌ក្រហម ឬទឹកក្រូច ឬនិងអាចធ្វើឱ្យស្បែកទៅជាខ្មៅ ។ ប៉ុន្តែ វានឹងបាត់ទៅវិញបន្តិចម្តងៗ ក្រោយពីបញ្ចប់ការព្យាបាល ។

ពេលខ្លះអ្នកជំងឺអាចមានប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងថ្នាំផងដែរ ។

បើអ្នកមិនប្រាកដក្នុងចិត្តពីបញ្ហាណាមួយ ឈប់លេបថ្នាំ ហើយទៅមណ្ឌលសុខភាពភ្លាម ។

អ្នកអាចទទួលបានថ្នាំផ្សេងៗទៀត ដើម្បីព្យាបាលជំងឺឃ្លង់ ប្រសិនបើចាំបាច់ ។

**បើអ្នកបារម្ភពីបញ្ហាណាមួយ សូមពិគ្រោះជាមួយបុគ្គលិកមណ្ឌលសុខភាពរបស់អ្នក**

## ប្រាប់ប្រជាជនឱ្យបានច្រើនអំពី



## សញ្ញាដំបូងរបស់ ជំងឺឃ្លង់

## កុំខ្លាចជំងឺឃ្លង់

**ជំងឺឃ្លង់អាចព្យាបាលជាសះស្បើយ១០០%**

# ត្រូវចងចាំ!

- ជំងឺឃ្លង់អាចកើតមានលើមនុស្សគ្រប់រូប
- ជំងឺឃ្លង់មិនងាយឆ្លង តែងាយស្រួលព្យាបាលជា
- ព្យាបាលដោយមិនគិតថ្លៃ
- ព្យាបាលទាន់ពេលអាចបង្ការភាពពិការ
- កុំពន្យារពេល សូមទៅមណ្ឌលសុខភាពថ្ងៃនេះ

IEC Materials Design and Development: Ponleu Sokhapheap (PSP)